យួនត្រួតត្រានៅស្រុកខ្មែរ មិនគោរពច្បាប់ខ្មែរ

សេរីការ

ពួកយួនកុម្មុយនិស្ត ត្រួតត្រានៅស្រុកខ្មែរ វាមិនគោរពច្បាប់ខ្មែរ ហើយ វានាំគ្នាប្រើប្រព័ន្ធយុទ្ធធម៌ខ្មែរ អោយបំពានច្បាប់ជាតិ ឥតរញ៉ាបន្ទិច បន្ទួចនោះឡើយ ដូចយ៉ាង ចាប់ខ្លួន លោក ហុង សុខហួរ, អ៊ុ សំអាន ដែល ជាបុគ្គល ប្រដាប់ដោយ អភ័យឯកសិទ្ធ ជា សមាជិកសភា[1]ជាតិ ហើយ បច្ចុប្បន្ននេះ មានបំណងចាប់ លោក កឹម សុខា, ប្រធានស្តីទី គណបក្សសង្គ្រោះជាតិ និង ជា តំណាងរាស្ត្រ ពីបទ មិនចូលខ្លួន បំភ្លឺ តុលាការ តាមដីកាកោះហៅ របស់ សុភាចារបុរស[2] ក្នុងហាន:ជា សាក្សី ក្នុងរឿង ពាក់ព័ន្ធនឹងសញ្ញារកម្ម។

ការរំឭក អំពីច្បាប់ខ្មែរ

ការរំឭក អំពីច្បាប់ខ្មែរ ដល់ពួកយួនត្រួតត្រានៅស្រុកខ្មែរ: ដីកា របស់ សុភាចារបុរស វាខុសច្បាប់ រដ្ឋធម្មនុញ្ញជាតិខ្មែរព្រោះ លោក កឹមសុខា, ដូចគ្នានឹង ករណី លោក ហុង សុខហួរ, អ៊ុ សំអាន, ជា បុគ្គល ប្រដាប់ ដោយ អភ័យឯកសិទ្ធ ក្នុង ហាន:គាត់ ជា សមាជិកសភា ដូចបានជំ រាបខាងលើរួចហើយ ; ដូច្នេះ បើគ្មានការអនុញ្ញាតពីរដ្ឋសភា តាមការ បោះឆ្នោត យល់ព្រមដកអភ័យឯកសិទ្ធិពីសមាជិកខ្លួន តុលាការគ្មាន នីតិសម្បទាន អាចកោះហៅសមាជិកសភាអោយចូលខ្លួនបំភ្លឺ ក្នុង ហា ន:ជាអ្វីមួយនោះឡើយ ហើយ នគរបាលព្រហ្មទណ្ឌ គ្មានអំណាចណាទៅ ចាប់ សមាជិកសភា បាននោះដែរ រៀរលែងតែបុគ្គលនោះ ប្រព្រឹត្តបទ ល្មើសជាក់ស្តែង។ ដូច្នេះ កោលាហល ដែលពួកយួន នៅស្រុកខ្មែរ កំពុង ធ្វើនេះ គឺ ច្បាស់ជាពួកទាំងនោះ ប្រើ ច្បាប់ ព្រៃ ឬ ច្បាប់ កុម្មុយនិស្ត

[1] សមាជិកសភា ; membres parlementaires។
[2] សុភាចារបុរស ; juge d'instruction។

ដែលពួកចៅហ្វាយខ្លួននៅស្រុកយួន ប្រើសំរាប់ រាយកំទិចអ្នកប្រឆាំង លទ្ធិកុម្មុយនិស្តយួន។

ការរំឭក អំពី ការចរចា

ការចរចា អាចមាន លទ្ធផលជាវិជ្ជមាន លុះត្រាតែ ដៃគូ នៃ ការចរចា មានគោលប្រយោជន៍រួម និង មាន កម្លាំងស្មើគ្នា, តែថា នៅស្រុកខ្មែរ យួនកុម្មុយនិស្ត និង ភាគីខ្មែរ ដែល ជាគណបក្សប្រឆាំង គ្មានអ្វីដែល អាចទុកជា គោលប្រយោជន៍រួម ហើយ គ្មានកម្លាំងស្មើគ្នា នោះឡើយ, ដូច្នេះការចរចា រកដំណោះស្រាយនយោបាយ គឺគ្មានអ្វីក្រៅពី ភាគីខ្មែរ ត្រូវតែ ទទួលយល់ព្រម តាមការចង់បាន របស់ភាគីយួន, តែងតួ ជាខ្មែរ, តែប៉ុណ្ណោះ ហើយ ការចរចា ជាមួយ គណបក្សកាន់អំណាច វាគ្មាន ប្រយោជន៍អ្វីនោះដែរ ព្រោះ គណបក្សនេះ ជា អាយ៉ងយួន ហើយ គ្មាន អំណាចអ្វី ធ្វើការសម្រេចលើអ្វីមួយ ដែលជាប្រយោជន៍ខ្មែរ ក្រៅពី មានអំណាចយួនប្រគល់អោយ សំរាប់ សម្លាប់ខ្មែរអ្នកប្រឆាំងនឹង ប្រយោជន៍យួន ក្នុងតួនាទីជាបាតដីទី៣។ ប្រតិកម្ម ទូតសហរដ្ឋអាមេរិក សូមឲបន្តរឬជម៍សន្ទនា គឺគ្រាន់តែជាសំដីខ្យល់គ្មានយកការពិត ខ្មែរ មកធ្វើជាគោលពិចារណាអ្វីបន្ទិចនោះឡើយ គឺថាដូចសូមអោយ ក្ងានចៀមបន្ត ការចរចា ជាមួយខ្លាអត់ឃ្លានចំណី យូរថ្ងៃមកហើយ។ យួនគ្មានប្រយោជន៍អ្វី អោយខ្មែរ មានសាមគ្គីភាពជាតិនោះជាដាច់ ខាត ហើយ ក៏មិនចង់អោយ លទ្ធិប្រជាធិបតេយ្យ មានជ័យជំនះនៅ ស្រុកខ្មែរព្រោះ វាជាគ្រោះថ្នាក់ ដល់យួន និង លទ្ធិកុម្មុយនិស្តខ្លួន ដូច្នេះ យួន បង្កើត ការរឹតរបាមអចិន្ត្រៃយ៍នៅស្រុកខ្មែរ។

ការរំឭក អំពី ទង្វើកាន់ច្រឡំ របស់គណបក្សប្រឆាំង

គណបក្សប្រឆាំងគ្មានយុទ្ធសាស្ត្រអ្វីច្បាស់លាស់ សំរាប់ប្រឆាំងនឹងគណ បក្សកាន់អំណាច ក្រៅពីដេកចាំបោះឆ្នោត ដោយសង្ឃឹមថា អាចនឹង

មានការបោះឆ្នោតមួយត្រឹមត្រូវព្រោះមាន គ.ជ.ប. ថ្មី។ មាយាការ[3]នេះ ឯង ដែលនាំឲគណបក្សប្រឆាំង ចុន[4] គិតតែរង នូវ ការវាយប្រហារ ឬ បំពាន គ្រប់បែបយ៉ាង មកលើខ្លួន រហូត គេហ៊ានវាយប្រហារ លោក សម រង្សី ដែលជាប្រមុខរបស់ខ្លួន ក៏គ្មាន ប្រតិកម្មសមាមាត្រនឹង[5] ទង្វើនេះដែរ បែរជាបង្កើត យុទ្ធសាស្ត្រ មិនឆ្លើយ, មិនឈ្លោះ ដែលជាយុទ្ធសាស្ត្រ សំរាប់ អ្នកខ្សោយ សូមរស់តែប៉ុណ្ណោះនៅក្នុង របបសិទ្ធិអំណាច។ អ្វីដែលបន្តកើតឡើងសព្វថ្ងៃនេះ គឺជា សមាជ័យ[6] នៃ ទង្វើភាន់ច្រឡំ របស់គណបក្សប្រឆាំងខ្លួនឯង តែកម្មផលវិញ គឺ ប្រជាពលរដ្ឋខ្មែរ ជាអ្នកទទួល ព្រោះ ជាការភាន់ច្រឡំ បើកឱកាស អោយយួន អាចពង្រឹងអំណាចគេបានងាយស្រួលបំផុតនៅស្រុកខ្មែរ បើនិយាយជាសង្ខេប គឺ អប្បបញ្ញា[7] នៃ ពួកអ្នកដឹងនាំគណបក្សប្រឆាំង ជា លាភជ័យ របស់ យួន នោះឯង។

ដំណោះស្រាយ

គឺគ្មានអ្វីក្រៅពីការរឹត មកវក ធាតុសារវន្ត របស់ខ្លួន ជា គណបក្ស ប្រឆាំង ដែលមានតួនាទីជា អ្នកប្រឆាំង ជា ពិសេស នៅក្នុង បរិបទ នៃជីវិតភាពនយោបាយខ្មែរ។ នាំគ្នាដេកចាំបោះឆ្នោត ជា និស្សកម្ម ; តែធ្វើសកម្មភាព ក្នុងហាន:ជា អ្នកប្រឆាំងនឹងអំណាចយួន ដើម្បីឲ មានការបោះឆ្នោតត្រឹមត្រូវ ជា សកម្មភាពវិជ្ជមាន ដូច្នេះ មិនត្រូវ ខ្លាច ធ្វើពិហិការ បើសិន លក្ខខណ្ឌ នៃ ការបោះឆ្នោត វាមិនស្របនឹង លទ្ធិប្រជាធិបតេយ្យ។ ការឈប់ធ្វើសហការ គ្រប់បែបយ៉ាង ទោះបីនៅ ក្នុងរដ្ឋសភា ជាមួយ គណបក្ស កាន់អំណាច ដែល ជា បក្សប៉ំរើ ប្រយោជន៍យួន គឺជា ការបង្ហាញ នូវគោលជំហរច្បាស់លាស់ ក្នុងហាន:

[3] មាយាការ ; illusion។
[4] ចុន ; tomber dans une impasse។
[5] ប្រតិកម្មសមាមាត្រនឹង ; réaction proportionnelle។
[6] សមាជ័យ ; accumulation។
[7] អប្បបញ្ញា ; médiocrité។

ជាអ្នកប្រជាធិបតេយ្យ។ តែបើ គណបក្សប្រឆាំង នៅតែមាន មាយាការ ថា ការចរចា ជាមួយគណបក្សកាន់អំណាច អាចរកឃើញដំណោះស្រាយ សំរាប់រកប្រយោជន៍ជាតិបាន គឺ ច្បាស់ជានាំគ្នា ការពារប្រយោជន៍យួនកុម្មុយនិស្ត ជាពុំខាន។ ត្រូវខ្មែរមានស្មារតីថា បញ្ហាខ្មែរ សព្វថ្ងៃ គឺជាបញ្ហា ខ្មែរនឹងយួន មិនមែនជា បញ្ហា ខ្មែរនិងខ្មែរ នោះឡើយ ព្រោះស្រុកខ្មែរ ជាស្រុករស់នៅក្រោមអាណានិគមយួន។ សព្វថ្ងៃ អង្គការសហប្រជាជាតិក្តី, សហគមន៍អន្តរជាតិក្តី, សហរដ្ឋអាមេរិកក្តី គេស្គាល់ បញ្ហាខ្មែរច្បាស់ណាស់ តែគេមើលឃើញថា កត្តា នៃ អប្បបញ្ហា នៃ អ្នកនយោបាយខ្មែរ ដែលជា បញ្ហា មិនអាច អោយខ្មែរជួយខ្លួនដោយខ្លួនឯងបាននោះឡើយ ដូច្នេះ គេមិនអាចប្រកាន់ជំហរណាមួយ ដើម្បី ជួយដោះ ស្រាយបញ្ហាខ្មែរ បើគេមើលមិនឃើញ នូវ ឧទ័យ (émergence) នៃ កម្លាំងជាតិខ្មែរ ណាមួយ កើតឡើង ដែល មានអ្នកដឹងនាំ មាន គុណសម្បត្តិ ជាអ្នកដឹកនាំជាតិ ពិតប្រាកដ ព្រោះ សម័យ ប៉ុល ពត នៅតែលងគេជានិច្ច ; មួយវិញទៀត ស្រុកខ្មែរ មិនមែនជាអាទិភាព នៃ នយោបាយអន្តរជាតិនោះឡើយ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា បើខ្មែរយើង មិនជួយខ្លួនឯង គឺ យួន គេជួយយួនគ្នាគេ អោយយកស្រុកខ្មែរ ធ្វើជាស្រុកយួននោះឯង៖